ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ ៤៤១ ហគ.កបទ.សអ

សេចក្តីជូនដំណឹង
ស្តីពីការដេញថ្លៃការផ្តត់ផ្គង់សម្ភារការិយាល័យ ឆ្នាំ២០២៣

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន ឬសហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈនូវការផ្តត់ផ្គង់សម្ភារការិយាល័យ ឆ្នាំ២០២៣ ដូចមានព័ត៌មានខាងក្រោម៖

-ឯកសារសម្រាប់ការចូលរួមដេញថ្លៃមានផ្តល់ជូន នៅអង្គភាពលទ្ធកម្មទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាសយដ្ឋានលេខ៣ វិថីសម្តេចហ៊ុនសែន សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃឈប់ទទួលពាក្យនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៩:០០ នាទីព្រឹកជាកំហិត
-ការបើកឯកសារដេញថ្លៃជាផ្លូវការ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង ០៩:០០នាទីព្រឹក នាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ នៅអាសយដ្ឋានខាងលើដដែល
-ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអង្គភាពលទ្ធកម្ម នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមអាសយដ្ឋានខាងលើនេះរៀងរាល់ម៉ោងធ្វើការ៕

ថ្ងៃ ពុធ ១០កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២៣

ជំទប់ទីប្រាំបីប្រធានគណៈកម្មាធិការលទ្ធកម្ម
អនុប្រធាន

ញឹម ខេមរា

ចម្លងជូន:
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh